**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជាថ្នាក់ដឹកនាំ និង **លោក លោកស្រី** ជាមន្ត្រីរាជការទាំងអស់នៃក្រសួងយុត្តិធម៌ ឱ្យបានជ្រាបថា ដោយផ្អែកតាម "**គោលការណ៍ណែនាំទូទៅស្តីពីការគ្រប់គ្រង និងប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩**" និងសារាចរបស់រាជរដ្ឋាភិបាល លេខ ០៤ សរ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការដាក់ចេញយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងយុត្តិធម៌នឹងរៀបចំឱ្យមានការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃពុធ ទី១១ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ៧:៣០ នាទីព្រឹក នៅទីស្តីការក្រសួងយុត្តិធម៌។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** ជាថ្នាក់ដឹកនាំ និង **លោក លោកស្រី** ជាមន្ត្រីរាជការទាំងអស់នៃក្រសួងយុត្តិធម៌ អញ្ជើញមកទទួលការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ តាមកាលបរិច្ឆេទ និងទីតាំងដែលបានកំណត់ខាងលើឱ្យបានគ្រប់ៗគ្នា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ អគ្គលេខាធិការដ្ឋាននឹងធ្វើការស្រង់វត្តមានថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅថ្ងៃធ្វើតេស្ត ទៅតាមតារាងដែលបានសម្របសម្រួលជាមួយអង្គភាពទាំងអស់ចំណុះឱ្យក្រសួងយុត្តិធម៌។ KR

ថ្ងៃព្រហស្បតិ៍ ១២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១